# រស្មីកម្ពុជា ប្រចាំថ្ងៃ

ក

RASMEI KAMPUCHEA DAILY NEWSPAPER

ឆ្នាំទី19 លេខ5428 ថ្ងៃសៅរ៍ ទី12 ខែកុម្ភៈ ឆ្នាំ2011 •ការិយាល័យគ្រប់គ្រង និងផ្សាយពាណិជ្ជកម្ម

TEL:023 726 655 Fax:023 217 172 ការិយាល័យនិពន្ធ TEL: 023 224 605 តម្លៃ 1000 រៀល

# ខដុមនៅទីក្រុងឡុងដ៍មកកាន់ភូមិដាច់ស្រយាលនៅប្រទេសកម្ពុជា



*លោកស្រីកន្ដារ៉ាវីន ធិនការេត សុខចិត្តចាកចេញពីកណ្ដាលក្រុងឡុងដ៍ មកកាន់ប្រទេសកម្ពុជាដើម្បីអភិវឌ្ឍន៍មាតុភូមិកំណើត*



*អណ្ដូងទឹកដែលផ្ដល់ពីមូលនិធិ ធិនការេត សម្រាប់កម្ពុជា*

ដើម្បីឱ្យបារមីថែរក្សាយើងទាំងអស់គ្នា ”។

រំលឹកដល់អតីតកាល លោកស្រីបានមានប្រសាសន៍ប្រកបដោយសុទិដ្ឋិនិយមថា ពួកបស្ចិមប្រទេសបាននិយាយថា ប្រជាជាតិខ្មែរចេះញញឹមជាមួយនឹងកែវភ្នែក ជាស្នាមញញឹមមួយមានតម្លៃលៃ និងកម្រជាតិសាសន៍ណាអាចធ្វើបាន ហើយប្រជាជនខ្មែរកាលមុនទសវត្សរ៍ទី៧០ ពេលទៅណា មកណា គេស្វាគមន៍គេរាប់រកនិងឱ្យតម្លៃ ប៉ុន្តែក្រោយរបបប៉ុល ពត បំផ្លិចបំផ្លាញគេចាប់ផ្ដើមស្គាល់ខ្មែរ មើលមកខ្មែរក្នុងរូបភាពផ្សេងពីមុន គេនិយាយប្រទេសខ្មែរថា Killing field ។

លោកស្រីកន្ដារ៉ាវីនបានមានប្រសាសន៍ថា “ការពិតខ្មែរមានវប្បធម៌ដ៏ផូរផង់ និងសម្បូរបែប មិនគួរមករលាយក្នុងរយៈពេលបីឆ្នាំ៨ខែ និង២០ថ្ងៃនោះទេ ប៉ុន្តែការពិតយើងមិនអាចប្រែកែបាន ដូច្នេះទើបខ្ញុំចង់កោសលុបស្លាកស្នាមអន្យតិរ្ថិយនេះចេញពីពួកប្រទេសទាំងនោះ ”។

ការពិតមិនមែនគាត់ចង់បំភ្លេចប្រវត្តិសាស្ត្រដ៏ខ្មៅងងឹត និងឃោរឃៅនោះទេ ប៉ុន្តែលោកស្រីមានបំណងចង់លុបបំបាត់ប្រមោលខ្មែរក្រហមចេញពីក្នុងជីវិតប្រជាជនខ្មែរ ចេញពីផ្នត់គំនិតពួកបស្ចិមប្រទេស និងបណ្ដាប្រទេសនានាដែលមើលងាយខ្មែរ។

លោកស្រីបានមានប្រសាសន៍ថា “ខ្ញុំមិនចង់ឱ្យគេបំភ្លេចខ្មែរក្រហមទេ ប៉ុន្តែសុំកុំបង្ហាញចេញមកច្រើនពេក ដែលយើងគួរលុបចេញ និងគួរបំភ្លេចចោល ប៉ុន្តែស្ថិតក្នុងការចងចាំរបស់យើងគ្រប់គ្រាន់ហើយ ”។ លោកស្រីបន្តថា “ខ្ញុំមានបំណង និងអំពាវនាវឱ្យប្រជាជនខ្មែរគ្រប់រូបមកទស្សនាអង្គរវត្តឱ្យបានម្ដងក្នុងមួយជីវិតពួកគេដើម្បីឱ្យពួកគេបួងសួង និងប្រាប់អាទិទេព និងបារមីទាំងឡាយនៅអង្គរទទួលស្គាល់ពួកគេថា ជាកូនរបស់ខ្មែរ ជាកូនចៅរបស់អាទិទេពទាំងឡាយទើបប្រទេសជាតិយើងបានសុខ និងសម្បូរសប្បាយ ”។

លោកស្រីបានទាញយកជំនឿរបស់ពួកមូស្លីមមកបញ្ជាក់ថា ប្រជាជនមូស្លីមទាំងអស់ ក្នុងមួយជីវិតរបស់ពួកគេ សុទ្ធតែត្រូវធ្វើយ៉ាងណាឱ្យបានទៅកាន់ទីសក្ការៈមេការ កន្លែងដែលព្រះអាឡោះចាប់កំណើត ហេតុនេះហើយទើប សង្គមរបស់ពួកគេមានក្ដីសុខ ដោយសារគេគោរពព្រះ និងបុព្វបុរសរបស់ពួកគេ ។

រំលឹកឡើងវិញពីរបាំផ្លិត ដែលលោកស្រីបង្កើតឡើង លោកស្រីកន្ដារ៉ាវីន បានមានប្រសាសន៍ថា ខ្ញុំចង់ឱ្យបេតិកភណ្ឌមរតកអរូបិយនេះ ជួយទ្រទ្រង់បេតិកភណ្ឌអរូបិឱ្យកាន់តែមានភាពរស់រវើកឡើង ”។

ដោយមិននឿយហត់នឹងការងារអភិវឌ្ឍន៍សហគមន៍របស់ខ្លួន លោកស្រីកន្ដារ៉ាវីន ធិនការេតមិនដែលត្អូញត្អែរក្នុងការចុះទៅកាន់សហគមន៍ ដែលរដូវវស្សាពេញដោយទឹកជក់ ភក់ជ្រាំ ហើយរដូវប្រាំងធូលីហុយសំពោង ដោយសារការបក់បោកនៃកម្លាំងខ្យល់ឡើយ ។

អ្នកស្រីបានមានប្រសាសន៍បន្តថា “នៅពេលខាងមុខនេះ ខ្ញុំនឹងនាំសៀវភៅចម្រៀងសន្តិភាព ដែលសរសេរជាភាសាអង់គ្លេសពោរពេញដោយ អត្ថន័យបកប្រែជាខ្មែរ ដើម្បីឱ្យប្រជាជនខ្មែរជាទីស្រលាញ់របស់ខ្ញុំបានច្រៀងចម្រៀងពោរពេញដោយអត្ថន័យនេះ ដើម្បីពួកគេអាចញញឹម ទៅកាន់ពិភពលោកជាមួយស្នាមញញឹមចេញពីកែវភ្នែកភ្លឺថ្លានិងបរិសុទ្ធរបស់ពួកគេ ”៕ **ប្រាយ ចំណាន**

# ដើម្បីស្នាមញញឹមរបស់ខ្មែរលោកស្រីកន្ដាវ៉ាវីនចាកចេញពីភាពសុ

**ភ្នំពេញ ៖** ដោយសារចង់ឃើញស្នាមញញឹមរបស់ប្រជាជនខ្មែរ ដែលពិភពលោកនិយាយថា ខ្មែរមានស្នាមញញឹមជាមួយកែវភ្នែក លោកស្រី កន្ដាវ៉ាវីន ឈិនការេត បានចាកចេញពីភាពសុខដុមនៅទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស មកកាន់ប្រទេសកម្ពុជា បន្ទាប់ពីលោកស្រី បានឃ្លាតអស់រយៈពេលយ៉ាងយូរ ។

លោកស្រីបានមកកាន់ប្រទេសកម្ពុជា និងចុះទៅកាន់ភូមិដាច់ស្រយាលក្នុងស្រុកបន្ទាយស្រី ខេត្តសៀមរាប កន្លែងដែលលោកស្រីបានជួយអប់រំ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធបម្រើសេចក្ដីត្រូវការរបស់អ្នកមូលដ្ឋាន ។ ពេលចុះទៅកាន់ទីនោះម្ដងៗ គាត់អង្គុយសំណេះសំណាលជាមួយកុមារបីដូចជាម្ដាយពួកគេបង្កើត គាត់អប់រំអ្នកភូមិបីដូចវេជ្ជបណ្ឌិតម្នាក់ អប់រំប្រជាជនឱ្យយល់ពីសុខភាពអ្នកមករកខ្លួនពិនិត្យជំងឺ ហើយគាត់សង់សាលារៀនក្នុងភូមិ ជាការរួមវិភាគទានជាមួយរាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្ដេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេដឹកនាំម្នាក់ដែលស្ថិតក្នុងការសរសើរពីដួងចិត្តលោកស្រីរហូតមក ។

លោកស្រីកន្ដាវ៉ាវីន ឈិនការេត បានមានប្រសាសន៍អំពីបេសកកម្មរបស់ខ្លួននៅកម្ពុជា កាលពីចុងសប្ដាហ៍កន្លងមកថា មូលនិធិឈិនការេតសម្រាប់កម្ពុជា បានខិតខំប្រមូលថវិកា ដើម្បីយកមកជួយអភិវឌ្ឍន៍ប្រទេស ដោយលោកស្រីបានយកប្រាក់ទាំងនោះមួយសេនណាដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ ផ្ទុយទៅវិញប្រជាជនចំនួន១៤ភូមិ រស់នៅក្នុងឃុំចំនួន៥ក្នុងស្រុកបន្ទាយស្រី បាននិងកំពុងទទួលបានការអប់រំ ការយល់ដឹងពីអនាម័យ មានអណ្ដូងទឹកស្អាត មានបង្គន់អនាម័យ បានទទួលការបណ្ដុះបណ្ដាលផ្នែកកសិកម្ម ធ្វើជីកំប៉ុស្ដិ៍ ដាំដំណាំ និងយល់ដឹងពីរបៀបទទួលទាន ដើម្បីបានទទួលអាហារូបត្ថម្ភគ្រប់គ្រាន់សម្រាប់រាងកាយ បង្រៀនពីវិធីការពារខ្លួនពីការកេងប្រវ័ញ្ចរាងកាយ និងផ្លូវភេទ ។

តាមរយៈមូលនិធិឈិនការេតសម្រាប់កម្ពុជាប្រជាជនក្នុងមូលដ្ឋាននេះ ក៏ទទួលបានការអប់រំពីផលវិបាកនៃអំពើហិង្សាក្នុងគ្រួសារ ពីផលវិបាកនៃការរស់នៅខ្វះអនាម័យ និងវិធីការពារកុំឱ្យឆ្លងជំងឺអេដស៍ជាដើម ។

កុមារក្នុងមូលដ្ឋានបានចូលរៀននៅសាលាចំនួនបីខ្នង ដែលលោកស្រីបានសាងសង់សម្រាប់អ្នកភូមិ ។

បច្ចុប្បន្នដោយសារមានជំនួយពីសប្បុរសជននានា ប្រជាជនចំនួន១៤ភូមិ ស្ថិតក្នុងឃុំចំនួន៥ ដែលមានប្រជាជនចំនួន២.៥០០គ្រួសារ និងមនុស្សសរុបជាង២៥.០០០នាក់បាន និងកំពុងទទួលបាននូវសមិទ្ធផល ដែលមូលនិធិផ្ដល់ជូន ។ ឃុំចំនួន៥នោះរួមមានឃុំត្បែង ឃុំខ្នាសណ្ដាយ ឃុំឃុនរាម ឃុំព្រះដាក់ និងឃុំរុនតាឯក ។

ភូមិនីមួយៗក្នុងមូលដ្ឋានខាងលើនេះ សុទ្ធតែត្រូវបានគូរផែនទី ដាក់លេខផ្លូវនិងលេខផ្ទះរបស់គ្រួសារនីមួយៗ ហើយគ្រប់ក្រុមគ្រួសារដែលមូលនិធិជួយទ្រទ្រង់ សុទ្ធតែមានសៀវភៅគ្រួសារតម្កល់នៅក្នុងការិយាល័យធ្វើការរបស់មូលនិធិ ដើម្បីបង្កភាពងាយស្រួលក្នុងការពិនិត្យមើលជំនួយ និងបញ្ហាដែលគ្រួសារនីមួយៗជួបប្រទះផងដែរ ។

ស្ត្រីដែលបានគេចចេញពីភាពស៊ីវិល័យមកទទួលអម្រែកធ្ងន់ធ្ងរ ដើម្បីចូលរួមអភិវឌ្ឍន៍ប្រទេសរូបនេះ បាននិងកំពុងប្រែក្លាយទីជនបទក្នុងខេត្តសៀមរាបឱ្យមានសាលាសិល្បៈបែបបណ្ឌិតសភាមួយ ដើម្បីបង្ហាត់របាំប្រពៃណីរបាំក្បាច់បុរាណ និងសិល្បៈគំនូរ នាពេលខាងមុខនេះ ដែលនេះជាបំណងប្រាថ្នាដ៏ធំរបស់លោកស្រី ដើម្បីនាំយករបាំទាំងនោះ ទៅធ្វើការបួងសួងនៅតាមប្រាសាទនានានៅទូទាំងប្រទេស។ លោកស្រី ក៏បានបង្កើតក្រុមភ្លេងពិណពាទ្យ ដែលមាននារីជាអ្នកលេងលើកដំបូងនៅកម្ពុជាផងដែរ បន្ទាប់ពីលោកស្រីមើលឃើញចម្លាក់នៅជញ្ជាំងប្រាសាទបាយ័ន ដែលបានបង្ហាញពីក្រុមភ្លេងពិណពាទ្យ ដែលមានសុទ្ធតែនារីជាអ្នកលេងថ្វាយព្រះបាទជ័យវរ្ម័នទី៧ និងអគ្គមហេសីរបស់ព្រះអង្គ ។

លោកស្រីកន្ដាវ៉ាវីន ឈិនការេតនៅតែដក់ជាប់នូវជំនឿជាច្រើន ដោយលោកស្រីបានមានប្រសាសន៍ថា របាំផ្កាដែលលោកស្រីបង្កើតឡើងសម្រាប់រាំថ្វាយអាទិទេពនៅគ្រប់ប្រាសាទទាំងអស់ និងសុំខមាលទោសចំពោះអាទិទេពទាំងនោះ ដែលមនុស្សជំនាន់ក្រោយហាក់បំភ្លេចចោល ហើយលោកស្រីមានបំណង និងសំណូមពរយ៉ាងទទូចឱ្យអ្នកទេសចរបរទេស និងអ្នកទេសចរក្នុងស្រុក មេត្តាដោះស្បែកជើងចេញពេលទៅកាន់ ឬដើរឡើងប្រាសាទណាមួយ ត្បិតការពាក់ស្បែកជើងដើរឡើងប្រាសាទមានន័យថា ជាការប្រមាថ ដល់អាទិទេព ទាំងឡាយដែលនៅតែមានបារមី ថែរក្សាប្រទេសកម្ពុជា ។

លោកស្រីកន្ដាវ៉ាវីន ដែលជាកូនកាត់ពួកបស្ចិមប្រទេស បានសម្ដែងនូវអារម្មណ៍សោកសៅ និងចង់ដាស់ប្រជាពលខ្មែរថា "កុំធ្វេសប្រហែសពេក និងកុំប្រមាថដល់អាទិទេពក្រុងអង្គរពិសេសប្រាសាទព្រះវិហារ ដោយលោកស្រីសំណូមពរឱ្យទាហានទាំងអស់ពេលឡើងប្រាសាទនេះ ឬប្រាសាទដទៃទៀត ត្រូវដោះស្បែកជើង និងមួកចេញ ហើយត្រូវអុជធូបរៀងរាល់ថ្ងៃ

សេចក្ដីស្រឡាញ់ (Valentine's Day) គឺ បាននិយាយ ថា